# ថ្នាំបង្ការរោគគ្រុនផ្ដាសាយធំ អសកម្ម

## អ្វីដែលលោកអ្នកត្រូវដឹង 2009-10

មានសេចក្ដីថ្លែងព័ត៌មានថ្នាំបង្ការរោគ ជាច្រើន ជាភាសាអង់គ្លេស និងភាសាផ្សេងៗទៀត ។ សូមមើលនៅ www.immunize.org/vis ។

## 1 តើហេតុអ្វីបានជាត្រូវទទួលថ្នាំបង្ការរោគ?

**គ្រុនផ្ដាសាយធំ "ហ្លូ" (flu) គឺជាជំងឺដែលឆ្លងរាលដាល ។**

គ្រុនផ្ដាសាយធំបានបណ្ដាលដោយសារ មេរោគវីរុសគ្រុនផ្ដាសាយធំ ដែលអាចឆ្លងតាមរយៈការក្អក ការកណ្ដាស់ ឬសំបោរ ។

រោគផ្សេងទៀតអាចមានសញ្ញារោគដូចគ្នា ហើយជាញឹកញាប់អាចច្រឡំថាជាគ្រុនផ្ដាសាយធំ ។ មានតែជំងឺម្យ៉ាងទេ ដែលបានបណ្ដាលដោយសារមេរោគវីរុសគ្រុនផ្ដាសាយធំ ដែលពិតជាគ្រុនផ្ដាសាយធំ ។

អ្នកណាក៏អាចកើតគ្រុនផ្ដាសាយធំនេះដែរ ប៉ុន្តែកើតធ្ងន់ធ្ងរខ្លាំងជាងគេ គឺក្នុងចំណោមកូនក្មេង ។ មនុស្សភាគច្រើន កើតរោគនេះតែពីរបីថ្ងៃប៉ុណ្ណោះ ។ វាអាចបណ្ដាលឲ្យ :

- គ្រុនក្ដៅ
- ឈឺបំពង់ក
- ស្រៀវស្រាញ
- អស់កំឡាំង
- ក្អក
- ឈឺក្បាល
- ឈឺសាច់ដុំ

មនុស្សខ្លះ ដូចជាទារក មនុស្សចាស់ៗ និងមនុស្សមួយចំនួនដែលមានបញ្ហាសុខភាពខ្លះ អាចឈឺកាន់តែធ្ងន់ធ្ងរឡើង ។ គ្រុនផ្ដាសាយធំ អាចបណ្ដាលឲ្យមានគ្រុនក្ដៅ និងហើមសួត ព្រមទាំងធ្វើឲ្យលក្ខណៈសុខភាពដែលមានស្រាប់ហើយកាន់តែធ្ងន់ធ្ងរឡើង ។ វាអាចបណ្ដាលឲ្យរាករូស និងប្រកាច់ក្នុងចំណោមកូនក្មេង ។ ជាមធ្យម មនុស្សចំនួន 226,000 នាក់ ត្រូវចូលមន្ទីរពេទ្យជារៀងរាល់ឆ្នាំ ដោយសារតែគ្រុនផ្ដាសាយធំ ហើយមនុស្សចំនួន 36,000 នាក់បានស្លាប់ - ភាគច្រើនជាមនុស្សចាស់ៗ ។

**ថ្នាំបង្ការរោគគ្រុនផ្ដាសាយធំ អាចការពារគ្រុនផ្ដាសាយធំបាន ។**

## 2 ថ្នាំបង្ការរោគគ្រុនផ្ដាសាយធំអសកម្ម

ថ្នាំបង្ការរោគគ្រុនផ្ដាសាយធំ តាមរដូវកាលមានពីរប្រភេទ :

1. **ថ្នាំបង្ការរោគគ្រុនផ្ដាសាយធំអសកម្ម** (ងាប់) ឬហៅថា "flu shot" (ថ្នាំចាក់ការពារគ្រុនផ្ដាសាយធំ) ត្រូវបានចាក់ដោយម្ជុលចូលទៅក្នុងសាច់ដុំ ។ 2. **ថ្នាំបង្ការរោគគ្រុនផ្ដាសាយធំរស់** (អន់ខ្សោយ) ត្រូវបានបាញ់ចូលតាមរន្ធច្រមុះ ។

> ថ្នាំបង្ការរោគគ្រុនផ្ដាសាយធំ "តាមរដូវកាល" ទាំងនេះ ត្រូវបានបង្កើតឡើងដើម្បីការពារគ្រុនផ្ដាសាយធំដែលកើតមានជាប្រចាំឆ្នាំ ។ វាមិនការពារប្រឆាំងនឹងរោគគ្រុនផ្ដាសាយធំរាតត្បាត H1N1 ឡើយ ។

*ថ្នាំបង្ការរោគនេះ គឺបានរៀបរាប់ក្នុងសេចក្ដីថ្លែងព័ត៌មានថ្នាំបង្ការរោគ មួយដោយឡែកទៀត ។*

មេរោគវីរុសគ្រុនផ្ដាសាយធំ គឺតែងតែផ្លាស់ប្ដូរជានិច្ច ។ ដោយសារហេតុនេះ ថ្នាំបង្ការរោគគ្រុនផ្ដាសាយធំត្រូវបានធ្វើឲ្យទាន់សភាពការណ៍ ជារៀងរាល់ឆ្នាំ ហើយការបង្ការរោគគួរគប្បីតែបានធ្វើជាប្រចាំឆ្នាំ ។

ជារៀងរាល់ឆ្នាំ ពួកអ្នកវិទ្យាសាស្ត្រខំព្យាយាមផ្គូរផ្គងមេរោគវីរុស ឲ្យត្រូវគ្នានឹងថ្នាំបង្ការរោគដែលងាយនឹងបណ្ដាលឲ្យកើតគ្រុនផ្ដាសាយធំនៅឆ្នាំនោះ ។ នៅពេលមានការផ្គូរផ្គងជិតត្រូវគ្នា ថ្នាំចាក់បង្ការរោគអាចការពារមនុស្សភាគច្រើន អំពីជំងឺធ្ងន់ធ្ងរជាប់ទាក់ទងនឹងរោគគ្រុនផ្ដាសាយធំ ។ ប៉ុន្តែសូម្បីតែនៅពេលគ្មាន ការផ្គូរផ្គងជិតត្រូវគ្នាក៏ដោយ ក៏ថ្នាំបង្ការរោគអាចការពារបានខ្លះដែរ ។ ថ្នាំបង្ការរោគគ្រុនផ្ដាសាយធំ នឹង*មិន*ការពារជំងឺ "ដូចគ្រុនផ្ដាសាយធំ" ដែលបណ្ដាលមកពីមេរោគវីរុស ផ្សេងៗទៀតឡើយ ។

វាប្រើពេលដល់ទៅ 2 អាទិត្យ ក្រោយពីការចាក់ថ្នាំបង្ការរោគ ទំរាំចាប់ផ្ដើមការពារបាន ។ ថ្នាំនេះអាចការពារគ្រុនផ្ដាសាយធំបានដល់ទៅមួយឆ្នាំ ។

ថ្នាំបង្ការរោគគ្រុនផ្ដាសាយធំអសកម្មមួយចំនួន មានសារធាតុម្យ៉ាងដែលត្រូវបានរក្សាទុក ហៅថា ធីមីរ៉ូសាល់ (thimerosal) ។ មនុស្សខ្លះបានឲ្យយោបល់ថាសារធាតុ ធីមីរ៉ូសាល់ អាចទាក់ទងនឹងបញ្ហានៃការធំលូតលាស់របស់កូនក្មេង ។ នៅក្នុងឆ្នាំ 2004 វិជ្ជាស្ថានពេទ្យបានពិនិត្យពិច័យការសិក្សាជាច្រើន ដោយរកមើលទ្រឹស្ដីនេះ ហើយបានសន្និដ្ឋានថាគ្មានភស្តុតាងទំនាក់ទំនងដូចនេះទេ ។ ថ្នាំបង្ការរោគគ្រុនផ្ដាសាយធំ ដែលគ្មានសារធាតុធីមីរ៉ូសាល់ ក៏មានដែរ ។

## 3 តើអ្នកណា គួរតែចាក់ថ្នាំបង្ការរោគគ្រុនផ្ដាសាយធំ អសកម្ម?

*មនុស្សណាម្នាក់ ដែលចង់**បន្ថយភាពឈឺថ្កាត់ បណ្ដាលដោយសារ**គ្រុនផ្ដាសាយធំ ឬ **ការចំឡងគ្រុនផ្ដាសាយធំទៅអ្នកដទៃទៀត** ។*

*ក្មេងៗទាំងអស់ **ពីអាយុ 6 ខែឡើងទៅ និងមនុស្សចាស់ៗទាំងអស់ :***

- ក្មេងៗទាំងអស់ ចាប់តាំងពីអាយុ 6 ខែ រហូតដល់អាយុ 18 ឆ្នាំ ។
- មនុស្សណាម្នាក់ អាយុ 50 ឆ្នាំ ឬចាស់ជាង ។

*មនុស្សណាម្នាក់ **ដែលឋិតក្នុងភាពគ្រោះថ្នាក់នៃគ្រុនផ្ដាសាយធំ** ឬ**ងាយនឹងត្រូវការនូវការព្យាបាលសុខភាព :***

- ស្ត្រីដែលនឹង**មានផ្ទៃពោះ** ក្នុងកំឡុងពេលរដូវគ្រុនផ្ដាសាយធំ ។
- មនុស្សណាម្នាក់ **ដែលមានបញ្ហាសុខភាពយូរអង្វែង** ជាមួយនឹង :
  - រោគបេះដូង
  - រោគដំរងនោម
  - រោគថ្លើម
  - រោគសួត
  - រោគនៃការបំបែកអាហារ ដូចជារោគទឹកនោមផ្អែម
  - រោគហឺត
  - រោគខ្វះឈាមក្រហម និងបញ្ហារោគឈាមផ្សេងៗទៀត
- មនុស្សណាម្នាក់ **ដែលខ្សោយខាងប្រព័ន្ធស៊ាំរោគ** ដោយព្រោះតែ :
  - រោគអេចអាយវី/អេដ្ស (HIV/AIDS) ឬរោគផ្សេងៗទៀត ដែលប៉ះពាល់ប្រព័ន្ធស៊ាំរោគ
  - ការព្យាបាលយូរអង្វែង ដោយប្រើថ្នាំដូចជា ថ្នាំស្តេរ៉ូយ
  - ការព្យាបាលរោគមហារីក ដោយប្រើអ៊ិច្ស-រ៉េ ឬឱសថ
- មនុស្សណាម្នាក់ **ដែលមានបញ្ហាខាងសាច់ដុំ ឬសរសៃប្រសាទអ្វីមួយ** (ដូចជាបញ្ហាប្រកាច់ ឬរោគវិកលចរិត) ដែលអាចបណ្ដាលឲ្យមានបញ្ហាខាងដកដង្ហើម ឬលេប ។
- មនុស្សណាម្នាក់ អាយុពី 6 ខែ រហូតដល់ 18 ឆ្នាំ ដែលទទួល**ការព្យាបាលដោយប្រើថ្នាំអាស្ពីរីនយូរលង់** (គេអាចនឹងកើតមាននិមិត្តហេតុរោគរេយី ដែលអង់គ្លេស ហៅថា Reye Syndrome បើគេមានគ្រុនផ្ដាសាយធំ) ។
- **ប្រជាជនរស់នៅក្នុងមន្ទីរថែទាំជនជរា** និង**មន្ទីរថែទាំជំងឺរ៉ាំរ៉ៃផ្សេងៗទៀត** ។

*មនុស្សណាម្នាក់ ដែលរស់នៅជាមួយ ឬមើលថែមនុស្សដែលឋិតក្នុងភាពគ្រោះថ្នាក់ខ្លាំងនឹងរោគគ្រុនផ្ដាសាយធំ :*

- **វេជ្ជបណ្ឌិត និងពេទ្យ** ។
- **ក្រុមគ្រួសារជិតស្និទ្ធ និងអ្នកមើលថែរក្សាក្មេងៗ** ចាប់តាំងពីកំណើត ដល់អាយុ 5 ឆ្នាំ ។
- **ក្រុមគ្រួសារជិតស្និទ្ធ និងអ្នកមើលថែរក្សា**នៃ
  - មនុស្សអាយុ 50 ឆ្នាំ និងចាស់ជាង ឬ
  - មនុស្សណាម្នាក់ ដែលមានលក្ខណៈរោគា ដែលធ្វើឲ្យគេឋិតក្នុងភាពគ្រោះថ្នាក់ខ្លាំងនឹងរោគគ្រុនផ្ដាសាយធំ ។

វេជ្ជបណ្ឌិត ក៏អាចឲ្យយោបល់ទៅលើការចាក់ថ្នាំបង្ការគ្រុនផ្ដាសាយជាប្រចាំឆ្នាំ សំរាប់ :

- មនុស្សដែលផ្ដល់**ការបំរើសំខាន់ៗក្នុងសហគមន៍** ។
- មនុស្សដែលរស់នៅក្នុង**ទីសំណាក់សំរាប់និស្សិត អ្នករស់នៅក្នុងមន្ទីរកែតម្រូវខ្លួន ឬក្នុងលក្ខណៈណែនណាន់តាន់តាប់** ដើម្បីការពារកុំឲ្យឆ្លងរាលដាល ។
- មនុស្សដែលឋិតក្នុងភាពគ្រោះថ្នាក់ខ្លាំង នៃគ្រុនផ្ដាសាយធំរើតឡើងវិញ ដែលបាន**ធ្វើដំណើរ**ទៅភាគខាងត្បូងពាក់កណ្ដាលផែនដី ក្នុងរវាងខែមេសា និងកញ្ញា ឬទៅប្រទេសក្ដៅ ឬការធ្វើដំណើរជាក្រុមទេសចរ នៅពេលណាមួយ ។

## 4 តើខ្ញុំគួរតែចាក់ថ្នាំបង្ការរោគគ្រុនផ្តាសាយធំនៅពេលណា?

អ្នកអាចទទួលថ្នាំបង្ការរោគ ភ្លាមបន្ទាប់ពីពេលមានថ្នាំ ដែលតាមធម្មតានៅក្នុងរដូវស្លឹកឈើជ្រុះ និងពេលដែលជំងឺកំពុងកើតមាន នៅក្នុងសហគមន៍របស់អ្នក ។ គ្រុនផ្តាសាយធំ អាចកើតមានឡើងក្នុងពេលណាមួយ ពីខែវិច្ឆិកា ដល់ខែឧសភា ប៉ុន្តែពេលវាមានសន្ទុះខ្លាំងបំផុត គឺក្នុងខែមករា ឬកុម្ភៈ ។ ការចាក់ថ្នាំបង្ការរោគ ក្នុងខែធ្នូ ឬក្រោយជាងនេះទៀត ក៏នៅតែផ្តល់ប្រយោជន៍ច្រើនក្នុងឆ្នាំនោះដែរ ។

មនុស្សភាគច្រើនត្រូវការថ្នាំបង្ការរោគគ្រុនផ្តាសាយធំតែម្តង ក្នុងមួយឆ្នាំ ។ **កូនក្មេងអាយុតិចជាង 9 ឆ្នាំ ដែលចាក់ថ្នាំបង្ការរោគគ្រុនផ្តាសាយធំជាលើកដំបូង** - ឬអ្នកដែលបានចាក់ថ្នាំបង្ការរោគគ្រុនផ្តាសាយធំលើកទីមួយ កាលពីរដូវកន្លងទៅ ប៉ុន្តែបានចាក់តែម្តង - គួរតែចាក់ 2 ដង ដោយឃ្លាតពីគ្នាយ៉ាងតិចបំផុត 4 អាទិត្យទើបការពារបាន ។

ថ្នាំបង្ការរោគគ្រុនផ្តាសាយធំ អាចផ្តល់ឲ្យនៅពេលព្រមគ្នា ជាមួយនឹងថ្នាំបង្ការរោគផ្សេងទៀតដែរ រួមទាំងថ្នាំបង្ការរោគហើមសួតផង ។

## 5 មនុស្សមួយចំនួន គួរតែពិភាក្សាជាមួយនឹងគ្រូពេទ្យ មុននឹងចាក់ថ្នាំបង្ការរោគគ្រុនផ្តាសាយធំ

មនុស្សមួយចំនួន មិនគួរគប្បីចាក់ថ្នាំបង្ការរោគគ្រុនផ្តាសាយធំអសកម្មទេ ឬគួរតែរង់ចាំសិន មុននឹងចាក់ថ្នាំ ។

- ត្រូវប្រាប់គ្រូពេទ្យរបស់អ្នក បើអ្នកមានប្រតិកម្ម**ខ្លាំង**អ្វីមួយ (យាយីអាយុជីវិត) ។ ការមានប្រតិកម្មនឹងថ្នាំបង្ការរោគគ្រុនផ្តាសាយធំ គឺកម្រមានណាស់ ។
  - ថ្នាំបង្ការរោគគ្រុនផ្តាសាយធំ បានបណ្តុះចេញពីពងសត្វ ។ មនុស្សដែលមានប្រតិកម្មខ្លាំងនឹងពងសត្វ មិនគួរគប្បីចាក់ថ្នាំបង្ការរោគនេះឡើយ ។
  - អ្នកដែលមានប្រតិកម្មខ្លាំងនឹងគ្រឿងផ្សំអ្វីមួយនៃថ្នាំបង្ការរោគ ក៏មិនគួរគប្បីចាក់ថ្នាំបង្ការរោគនេះដែរ ។
  - បើអ្នកធ្លាប់មានប្រតិកម្មខ្លាំង បន្ទាប់ពីចាក់ថ្នាំបង្ការរោគគ្រុនផ្តាសាយធំពីមុនៗ ត្រូវប្រាប់គ្រូពេទ្យរបស់អ្នក ។
- ប្រាប់គ្រូពេទ្យរបស់អ្នក បើអ្នកធ្លាប់មានរោគ Guillain-Barré Syndrome (ជារោគកំរើកពុលរួចដ៏ធ្ងន់ធ្ងរ ដែលហៅកាត់ថា GBS ដែរ) ។ អ្នកអាចចាក់ថ្នាំបង្ការរោគនេះ ប៉ុន្តែគ្រូពេទ្យរបស់អ្នកគួរតែជួយអ្នកធ្វើការសំរេច ។
- មនុស្សដែលឈឺថ្កាត់មធ្យម ឬខ្លាំង តាមធម្មតាគួរតែរង់ចាំរហូតទាល់តែជាសះស្បើយ មុននឹងចាក់ថ្នាំបង្ការរោគគ្រុនផ្តាសាយធំ ។ បើអ្នកឈឺថ្កាត់ ត្រូវពិគ្រោះជាមួយគ្រូពេទ្យ ឬពេទ្យរបស់អ្នក ថាតើគួរតែណាត់ពេលចាក់ថ្នាំបង្ការរោគលើកក្រោយទៀត ឬជាយ៉ាងណា ។ មនុស្សដែលឈឺថ្កាត់ស្រាលៗ តាមធម្មតាអាចចាក់ថ្នាំបង្ការរោគនេះបាន ។

## 6 តើមានគ្រោះថ្នាក់អ្វីខ្លះ បណ្តាលពីថ្នាំបង្ការរោគគ្រុនផ្តាសាយធំអសកម្ម?

ថ្នាំបង្ការរោគ ក៏ដូចនឹងថ្នាំផ្សេងៗទៀតដែរ វាអាចបណ្តាលឲ្យមានបញ្ហាធ្ងន់ធ្ងរ ដូចជាមានប្រតិកម្មខ្លាំង ជាដើម ។ ភាពគ្រោះថ្នាក់នៃថ្នាំបង្ការរោគ ដែលបណ្តាលឲ្យគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬស្លាប់ គឺមានតិចតួចណាស់ ។

បញ្ហាធ្ងន់ធ្ងរបណ្តាលពីថ្នាំបង្ការរោគគ្រុនផ្តាសាយធំ គឺកម្រមានណាស់ ។ មេរោគវីរុសនៅក្នុងថ្នាំបង្ការរោគគ្រុនផ្តាសាយធំ ត្រូវបានសំឡាប់ ម៉្លោះហើយអ្នកមិនអាចកើតគ្រុនផ្តាសាយធំ ពីថ្នាំបង្ការរោគឡើយ ។

**បញ្ហាស្រាលៗ :**

- ឈឺសង្កៀរ ឡើងក្រហម ឬហើមនៅត្រង់កន្លែងមុខម្ជុល
- ស្អកសំឡេង ឈឺបំពង់ក ឬក្រហមភ្នែក ក្អក និងរមាស់
- គ្រុនក្តៅ
- ឈឺចាប់

បើមានបញ្ហាទាំងនេះកើតឡើង តាមធម្មតាវាចាប់ផ្តើមភ្លាមបន្ទាប់ពីបានចាក់ថ្នាំ ហើយមានរយៈពេលពី 1-2 ថ្ងៃ ។

**បញ្ហាធ្ងន់ធ្ងរ :**

- ប្រតិកម្មដែលយាយីអាយុជីវិត បណ្តាលពីថ្នាំបង្ការរោគ គឺកម្រមានណាស់ ។ បើសិនជាវាកើតឡើង តាមធម្មតាវាមានក្នុងពេលពីរបីនាទី ទៅពីរបីម៉ោង បន្ទាប់ពីបានចាក់ថ្នាំ ។
- នៅក្នុងឆ្នាំ 1976 ថ្នាំបង្ការរោគគ្រុនផ្តាសាយធំមួយប្រភេទហៅថា គ្រុនផ្តាសាយជ្រូក (swine flu) ទាក់ទងនឹងរោគ Guillain-Barré Syndrome (GBS) ។ ចាប់តាំងពីគ្រានោះមក ថ្នាំបង្ការរោគគ្រុនផ្តាសាយធំពុំបានបង្ហាញច្បាស់លាស់ ថាទាក់ទងនឹងរោគ GBS ទេ ។ ក៏ប៉ុន្តែបើមានគ្រោះថ្នាក់នៃរោគ GBS បណ្តាលមកពីថ្នាំបង្ការរោគគ្រុនផ្តាសាយធំ ក្នុងពេលបច្ចុប្បន្ននេះ វានឹងពុំមានលើសពី 1 ឬ 2 ករណីក្នុងបណ្តាមនុស្សមួយលាននាក់ ដែលបានចាក់ថ្នាំបង្ការរោគឡើយ ។ នេះគឺតិចយ៉ាងអនេក បើប្រៀបទៅនឹងភាពគ្រោះថ្នាក់ ធ្ងន់ធ្ងរអំពីគ្រុនផ្តាសាយធំ ដែលអាចការពារបានដោយការចាក់ថ្នាំបង្ការរោគ ។

## 7 ចុះបើសិនជាមានប្រតិកម្មធ្ងន់ធ្ងរវិញនោះ?

**តើខ្ញុំគួរតែឃ្លាំរកមើលអ្វី?**

លក្ខណៈចំឡែកអ្វីមួយខុសពីធម្មតា ដូចជាគ្រុនក្តៅខ្លាំង ឬអាកប្បកិរិយាប្រែប្រួល ។ សញ្ញានៃប្រតិកម្មធ្ងន់ធ្ងរ អាចរួមមាន ការពិបាកដកដង្ហើម ស្អកសំឡេង ឬការតឹងដង្ហើម មានកន្ទួលលើស្បែក ស្លេកស្លាំង ខ្សោយកំឡាំង ចង្វាក់បេះដូងដើរញាប់ៗ ឬវិលមុខ ។

**តើខ្ញុំត្រូវធ្វើយ៉ាងណា?**

- **ទូរស័ព្ទ**ទៅគ្រូពេទ្យ ឬយកមនុស្សនោះទៅជួបគ្រូពេទ្យជាបន្ទាន់ ។
- **ប្រាប់**គ្រូពេទ្យ អំពីអ្វីដែលបានកើតឡើង បានកើតឡើងនៅថ្ងៃខែឆ្នាំណា និងវេលាម៉ោងប៉ុន្មាន ហើយបានទទួលថ្នាំបង្ការរោគពីពេលណា ។
- **ស្នើ**គ្រូពេទ្យរបស់អ្នក ឲ្យរាយការណ៍អំពីប្រតិកម្ម ដោយបំពេញក្រដាសប្រព័ន្ធរបាយការណ៍ព្រឹត្តិការណ៍ប្រតិកម្មថ្នាំបង្ការរោគ (Vaccine Adverse Event Reporting System - VAERS) ។ ឬអ្នកអាចបំពេញសេចក្តីរាយការណ៍នេះ តាមរយៈវ៉ិបសៃត៍របស់ VAERS នៅឯ www.vaers.hhs.gov ឬដោយទូរស័ព្ទទៅលេខ 1-800-822-7967 ។

*VAERS មិនផ្តល់ឱវាទផ្នែកសុខភាពឡើយ ។*

## 8 កម្មវិធីជាតិ ធានារ៉ាប់រងគ្រោះថ្នាក់បណ្តាលពីថ្នាំបង្ការរោគ

កម្មវិធីរដ្ឋបាលសហព័ន្ធមានជាស្រាប់ ដើម្បីជួយបង់ថ្លៃការថែទាំមនុស្សណាម្នាក់ ដែលមានប្រតិកម្មធ្ងន់ធ្ងរ ដោយថ្នាំបង្ការរោគ ។

សំរាប់ព័ត៌មានបន្ថែមស្តីអំពី កម្មវិធីជាតិ សំណងគ្រោះថ្នាក់បណ្តាលពីថ្នាំបង្ការរោគ (National Vaccine Injury Compensation Program) សូមទូរស័ព្ទទៅលេខ **1-800-338-2382** ឬមើលវ៉ិបសៃត៍របស់គេនៅ **www.hrsa.gov/vaccinecompensation** ។

## 9 តើខ្ញុំធ្វើយ៉ាងណា ឲ្យបានយល់ដឹងបន្ថែមទៀត?

- សាកសួរគ្រូពេទ្យរបស់អ្នក ។ គេអាចផ្តល់ព័ត៌មានដែលមានភ្ជាប់ជាមួយប្រអប់ថ្នាំ ឬផ្តល់យោបល់ពីព័ត៌មានប្រភពផ្សេងៗទៀត ។
- សូមទូរស័ព្ទទៅក្រសួងសុខាភិបាលប្រចាំតំបន់ ឬក្រសួងសុខាភិបាលរដ្ឋ ។
- សូមទាក់ទងទៅមណ្ឌលទប់ស្កាត់ និងបង្ការរោគ (Centers for Disease Control and Prevention - CDC) :
  - សូមទូរស័ព្ទទៅលេខ **1-800-232-4636 (1-800-CDC-INFO)** ឬ
  - សូមមើលវ៉ិបសៃត៍របស់ CDC នៅ **www.cdc.gov/flu**

**DEPARTMENT OF HEALTH AND HUMAN SERVICES**
CENTERS FOR DISEASE CONTROL AND PREVENTION

Vaccine Information Statement (Interim) 42 U.S.C. §300aa-26
Inactivated Influenza Vaccine IMM-569CAM – Cambodian (8/11/09)
Translated by Transcend Translations, Davis, CA www.transcend.net